**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១២៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅ របស់មជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ កំណត់ការរៀបចំ និងប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ ។

មជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ ហៅកាត់ថា "ម.ជ.ឧ.ក.ព.ជ" ភាសាអង់គ្លេស "NATIONAL DEFENSE INDUSTRIAL CENTER " ហៅកាត់ថា "N D I C" ដែលជាស្ថាប័នមួយដែលស្ថិតនៅក្រោមការដឹកនាំ និងបញ្ជាផ្ទាល់ពីរដ្ឋមន្ត្រីក្រសួងការពារជាតិ ។

## ជំពូកទី ២
## តួនាទី និងភារកិច្ច

**មាត្រា២.-**

មជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ មានតួនាទីជាសេនាធិការជូនក្រសួងការពារជាតិ លើការងារដឹកនាំ គ្រប់គ្រង រៀបចំ ចាត់ចែងរាល់ការងារឧស្សាហកម្មការពារជាតិ រចនា កែច្នៃ ស្រាវជ្រាវ ពិសោធន៍ អភិវឌ្ឍន៍ផលិតកម្ម សព្វាវុធ គ្រាប់រំសេវ យុទ្ធោបករណ៍ គ្រឿងបំពាក់ គ្រឿងចក្រ ឧបករណ៍ សម្ភារៈ បរិក្ខារអេឡិចត្រូនិចគ្រប់ប្រភេទ សារធាតុគីមី ជីវសាស្ត្រ និងធ្វើពាណិជ្ជកម្ម វិនិយោគក្នុងវិស័យឧស្សាហកម្មការពារជាតិ ដើម្បីផលិតធានាជូនទៅតាម ផែនការសេចក្តីត្រូវការរបស់កងយោធពលខេមរភូមិន្ទ សម្រាប់ជាខឿនការពារជាតិ ។

**មាត្រា៣.-**

មជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ មានភារកិច្ចដូចខាងក្រោម៖

- ដឹកនាំសម្របសម្រួល និងតាមដានការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រ ទិសដៅ និងផែនការអភិវឌ្ឍន៍ក្នុងវិស័យ ឧស្សាហកម្មការពារជាតិ
- ដឹកនាំ គ្រប់គ្រង រៀបចំគោលនយោបាយ កម្មវិធីអភិវឌ្ឍន៍ និងធ្វើជាអាណាព្យាបាលលើរោងចក្រ សហគ្រាស និងគ្រឹះស្ថានសាធារណៈដែលបម្រើដល់វិស័យឧស្សាហកម្ម ផលិតកម្មការពារជាតិ
- ផលិតអាវុធយុទ្ធភណ្ឌ គ្រាប់រំសេវ យុទ្ធោបករណ៍ គ្រឿងបំពាក់ គ្រឿងចក្រ ឧបករណ៍ សម្ភារៈ មធ្យោបាយធ្វើដំណើរ-ដឹកជញ្ជូន មធ្យោបាយទំនាក់ទំនង ទូរស័ព្ទ វិទ្យុ រ៉ាដា ឧបករណ៍អេឡិចត្រូនិចនាំផ្លូវដោយផ្កាយរណប និងគ្រឿងអេឡិចត្រូនិចសម្រាប់ធានាជូនកងយោធពលខេមរភូមិន្ទ
- គ្រប់គ្រង វាយតម្លៃ ទទួលស្គាល់ ផ្តល់វិញ្ញាបនបត្រអនុលោមទៅតាមច្បាប់ស្តីពីស្តង់ដាររបស់ ព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីស្តង់ដារឧស្សាហកម្មការពារជាតិ
- ទំនាក់ទំនង សហប្រតិបត្តិការក្នុង និងក្រៅប្រទេសដើម្បីធ្វើការស្រាវជ្រាវរបកគំហើញវិទ្យាសាស្ត្រ ក្នុងគោលដៅបម្រើ អភិវឌ្ឍន កសាងសហគ្រាស រោងចក្រ មូលដ្ឋានអភិវឌ្ឍន៍ មូលដ្ឋានពិសោធន៍ រចនា កែច្នៃ ផលិត បង្កប្រភព គ្រឿងចក្រ អាវុធយុទ្ធភណ្ឌ នាវា យានយន្ត គ្រាប់ រំសេវ ឧបករណ៍ សម្ភារៈ បរិក្ខារអេឡិចត្រូនិច សារធាតុគីមី ជីវសាស្ត្រ មធ្យោបាយធ្វើដំណើរ-ដឹកជញ្ជូន តាមផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស រោងជាង ឃ្លាំងវិទ្យុរ៉ាដានាំផ្លូវរ៉ាដាល្បាត និងរ៉ាដាការពារដែនអាកាស ក្នុងគោលដៅជម្រុញឧស្សាហកម្មការពារជាតិ សម្រាប់ធានាដល់ការប្រតិបត្តិការសឹក និងដើម្បីត្រៀមបម្រុងក្នុងសភាពការណ៍បន្ទាន់របស់កងយោធពលខេមរភូមិន្ទ
- ធ្វើទីផ្សារ បង្កប្រភព វិនិយោគ ពាណិជ្ជកម្មនាំចេញ-នាំចូល ដើម្បីធានាដល់រាល់សង្វាក់ផលិតកម្ម ឧស្សាហកម្មការពារជាតិ
- គ្រប់គ្រងបរិមាណ ត្រួតពិនិត្យ ធ្វើតេស្តសាកល្បង ពិសោធន៍ជាមុន ដើម្បីធានាគុណភាព សុវត្ថិភាព ប្រសិទ្ធភាពមុននឹងបំពាក់ជូនកងយោធពលខេមរភូមិន្ទ
- គ្រប់គ្រង វាយតម្លៃ ទទួលស្គាល់ ផ្សព្វផ្សាយ និងផ្តល់វិញ្ញាបនបត្រ ប្រកាសនីយបត្រតក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម
- ចុះបញ្ជី និងទុកដាក់ថែរក្សានូវរាល់ឧបករណ៍ សម្ភារៈ គ្រឿងចក្រ យុទ្ធោបករណ៍ អាវុធយុទ្ធភណ្ឌ មធ្យោបាយធ្វើដំណើរ-ដឹកជញ្ជូន គ្រឿងអេឡិចត្រូនិច នៅគ្រប់បណ្តាសហគ្រាស រោងចក្រនីមួយៗ
- គ្រប់គ្រង ត្រួតពិនិត្យឃ្លាំងចំណុះមជ្ឈមណ្ឌលឧស្សហកម្មការពារជាតិ ទីកន្លែងរក្សាទុកដាក់អាវុធយុទ្ធភណ្ឌ យុទ្ធោបករណ៍ គ្រឿងចក្រ គ្រាប់រំសេវនៅតាមបណ្តាកងឯកភាព សហគ្រាស រោងចក្រ ក្រុមហ៊ុន សិប្បកម្មដែលចំណុះឱ្យមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ
- កសាងច្បាប់ បទបញ្ជា គោលការណ៍ផ្សេងៗ អនុលោមទៅតាមរដ្ឋធម្មនុញ្ញ បទបញ្ញត្តិ ច្បាប់ផ្សេងៗ ក្នុងវិស័យការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា

- រៀបចំរចនាសម្ព័ន្ធ និងលើកគម្រោងបណ្តុះបណ្តាល គ្រប់គ្រងរក្សាទុកតំណែងបុគ្គលិក ជំនាញឯកទេស វិស្វករ ដែលបានចាត់តាំងនៅតាមបណ្តាកងឯកភាពចំណុះនីមួយៗ
- ក្រៅពីភារកិច្ចខាងលើនេះមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ ត្រូវបានទទួលភារកិច្ចបន្ថែមទៀតតាមការប្រគល់ភារកិច្ចរបស់ក្រសួងការពារជាតិ ។

## ជំពូកទី ៣
## រចនាសម្ព័ន្ធ និងគ្រប់គ្រង

**មាត្រា៤.-**

មជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ ដឹកនាំដោយ អគ្គនាយកមួយរូប និង អគ្គនាយករងមួយចំនួនជាជំនួយការ ។

រចនាសម្ព័ន្ធចាត់តាំងមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិរួមមាន៖

១. លេខាធិការដ្ឋាន

២. ជំនាញគ្រប់គ្រងបុគ្គលិក

៣. ជំនាញគ្រប់គ្រងភស្តុភារ ហិរញ្ញវត្ថុ និងសុខាភិបាល

៤. ជំនាញត្រួតពិនិត្យ

៥. ជំនាញគ្រប់គ្រងសម្ភារៈ

៦. មូលដ្ឋានតេស្តសាកល្បង និងពិសោធន៍

៧. នាយកដ្ឋានផែនការ

៨. នាយកដ្ឋានត្រួតពិនិត្យគុណភាព និងស្តង់ដារផលិតកម្ម

៩. នាយកដ្ឋានសហប្រតិបត្តិការឧស្សាហកម្មយោធាស៊ីវិល

១០. សហគ្រាសអាវុធថ្មើរជើង

១១. សហគ្រាសកាំភ្លើងធំដី

១២. សហគ្រាសផលិតកម្មគីមីសាស្ត្រ

១៣. សហគ្រាសយានយន្ត

១៤. សហគ្រាសផលិតគ្រឿងអេឡិចត្រូនិច

១៥. សហគ្រាសរំសេវផ្ទុះ

១៦. សហគ្រាសយន្តសាស្ត្រ

១៧. សហគ្រាសផលិតអាវុធការពារអាកាស

១៨. សហគ្រាសផលិតនាវា

១៩. សហគ្រាសផលិតបរិក្ខារអគ្គិសនី

២០. វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ឧស្សាហកម្មការពារជាតិ

២១. ការិយាល័យ និងអង្គភាពចំណុះផ្ទាល់រួមមាន៖

- ការិយាល័យព័ត៌មានវិទ្យា
- ការិយាល័យប្រវត្តិសាស្ត្រយោធា
- វរសេនាតូចដឹកជញ្ជូន
- វរសេនាតូចការពារ

- បណ្តារោងជាង
- បណ្តាឃ្លាំង

(ភ្ជាប់មកជាមួយនូវរចនាសម្ព័ន្ធចាត់តាំង និងក្របខ័ណ្ឌ)

**មាត្រា៥.-**

លេខាធិការដ្ឋានមានតួនាទី និងភារកិច្ចដូចតទៅ៖

- មានតួនាទីជាសេនាធិការជូនមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិលើការងារលិខិតស្នាម និងឯកសារ រដ្ឋបាលផ្សេងៗ
- សម្រួលការងារលិខិតស្នាមក្នុងមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ
- ទទួលទុកដាក់ឯកសារ និងបែងចែកលិខិតស្នាម
- សិក្សាស្រាវជ្រាវ គ្រប់គ្រងលិខិតបទដ្ឋាន ឯកសាររដ្ឋបាលផ្សេងៗ
- សម្របសម្រួល ទំនាក់ទំនង កិច្ចការរដ្ឋបាល លិខិតបទដ្ឋាន ជាមួយស្ថាប័ន ក្រសួង សហគ្រាស រោងចក្រ ក្រុមហ៊ុន ស្ថាប័នជាតិ និងអន្តរជាតិដែលពាក់ព័ន្ធការងារឧស្សាហកម្មការពារជាតិ
- រៀបចំកិច្ចប្រជុំ សន្និបាត និងពិធីការផ្សេងៗ
- តម្កល់ ត្រួតពិនិត្យរាល់សំណើ គម្រោងផែនការ លិខិតចេញទៅបណ្តាកងឯកភាព ស្ថាប័នពាក់ព័ន្ធ ផ្សព្វផ្សាយ ជូនដំណឹង និងកត់ត្រា ទទួលបញ្ជូន នូវរាល់ឯកសារ ចេញ-ចូលទាំងអស់
- ពិនិត្យឯកសាររបស់អង្គភាពចំណុះ មជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ ដើម្បីដាក់ជូនអគ្គនាយក ពិនិត្យ និងសម្រេច
- ប្រមូលផ្តុំឯកសារកិច្ចព្រមព្រៀង កំណត់ហេតុ របាយការណ៍ និងអនុសាសន៍របស់ថ្នាក់ដឹកនាំ
- ក្រៅពីភារកិច្ចខាងលើនេះលេខាធិការដ្ឋាន ត្រូវទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិប្រគល់ជូន។

លេខាធិការដ្ឋាន ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន អមដោយអនុប្រធានមួយចំនួន មានឋានៈស្មើ អនុប្រធាននាយកដ្ឋាន ។

**មាត្រា៦.-**

ជំនាញគ្រប់គ្រងបុគ្គលិកមានតួនាទី និងភារកិច្ចដូចតទៅ៖

- មានតួនាទីជាសេនាធិការជូនមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិលើការងារ គ្រប់គ្រងកងទ័ព បង្កប្រភពកម្លាំងកងទ័ព ជ្រើសរើសបញ្ចូលក្របខ័ណ្ឌកងយោធពលខេមរភូមិន្ទ បុគ្គលិកជាវិស្វករ ជំនាញឯកទេស ជំនាញការជាតិ ជំនាញការអន្តរជាតិ មន្ត្រីជាប់កិច្ចសន្យា មន្ត្រីក្នុងមុខងារសាធារណៈ បម្រើការងារនៅតាមបណ្តាស្ថាប័ន សហគ្រាស រោងចក្រ ក្រុមហ៊ុន និងអង្គភាពចំណុះ មជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ
- មានភារកិច្ចគ្រប់គ្រងចំនួនទ័ពអំពីបរិមាណ និងគុណភាពរួមក្នុងក្របខ័ណ្ឌ មជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ
- រៀបចំរចនាសម្ព័ន្ធចាត់តាំងទៅតាមជំនាញនីមួយៗ របស់បណ្តាស្ថាប័នជំនាញ នាយកដ្ឋាន សហគ្រាស រោងចក្រ ក្រុមហ៊ុន និងអង្គភាពចំណុះមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ
- សិក្សាស្រាវជ្រាវ រាល់ក្របខ័ណ្ឌរចនាសម្ព័ន្ធចាត់តាំងជាតិ និងអន្តរជាតិ របស់បណ្តាស្ថាប័នជំនាញ នាយកដ្ឋាន សហគ្រាស រោងចក្រ ក្រុមហ៊ុន ដែលមានសកម្មភាពឧស្សាហកម្ម ផលិតកម្ម ប្រហាក់ប្រហែលនឹងមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ
- សហការ សម្របសម្រួល ទំនាក់ទំនង បង្កប្រភព រៀបចំឯកសារពាក់ព័ន្ធនានារបស់បុគ្គលិកជាវិស្វករ ជំនាញឯកទេស ជំនាញការជាតិ ជំនាញការអន្តរជាតិ មន្ត្រីជាប់កិច្ចសន្យា មន្ត្រីក្នុងមុខងារសាធារណៈ សម្រាប់ធានាបម្រើការងារជំនាញស្របតាមផែនការយុទ្ធសាស្ត្រ និងសេចក្តីត្រូវការចាំបាច់របស់មជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ
- លើកគោលការណ៍ និងធ្វើការបញ្ជូននាយទាហាន នាយទាហានរង និងពលទាហានដើម្បីបណ្តុះបណ្តាល ហ្វឹកហ្វឺនបំប៉នសមត្ថភាពតាមផែនការថ្នាក់លើ

៤

- វាយតម្លៃ បែងចែកប្រភេទដើម្បីសរសើរ និងដាក់វិន័យ គ្រប់គ្រងថែរក្សាឯកសារ (តាមប្រព័ន្ធទិន្នន័យ) ប្រវត្តិរូប យោធិន ព្រមទាំងយោធិនពលី មរណៈ ពិការ យោធិនបាត់បង់សមត្ថភាពការងារ យោធិនសោធននិវត្តន៍ អត្តសញ្ញាណប័ណ្ណ និងឯកសារផ្សេងៗទៀតដែលទាក់ទងនឹងការងារគ្រប់គ្រងទ័ព
- បង្កប្រភព រៀបចំឯកសារពាក់ព័ន្ធនានារបស់យោធិន សុំបញ្ចូលក្របខ័ណ្ឌថ្មី ក្នុងកងយោធពលខេមរភូមិន្ទ តាមការសម្រេចរបស់ក្រសួងការពារជាតិ និងរាជរដ្ឋាភិបាល
- រៀបចំបែបបទ សំណុំលិខិតតែងតាំងផ្លាស់ប្តូរមុខងារ តម្លើងឋានន្តរសក្តិ ជូនរង្វាន់ លិខិតសរសើរ ប័ណ្ណ សរសើរ គ្រឿងឥស្សរិយយស តួនាទី និងមុខងារតាមស្មាដៃ ជូនកងឯកភាព បុគ្គល ប្រភេទទ័ព ទ័ពជំនាញ បុគ្គលិកជាវិស្វករ ជំនាញឯកទេស ជំនាញការជាតិ ជំនាញការអន្តរជាតិ មន្ត្រីជាប់កិច្ចសន្យា មន្ត្រីក្នុងមុខងារសាធារណៈ គ្រប់គ្រង ត្រួតពិនិត្យ និងបូកសរុបទិន្នន័យ របាយការណ៍ ស្ថិតិចំនួនទ័ព នាយទាហាន មន្ត្រី បុគ្គលិក យោធិន បុគ្គលិកជាវិស្វករ ជំនាញឯកទេស ជំនាញការជាតិ ជំនាញការអន្តរជាតិ មន្ត្រីជាប់កិច្ចសន្យា មន្ត្រីក្នុងមុខងារសាធារណៈ ដែលបម្រើការក្នុងមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ
- ក្រៅពីភារកិច្ចខាងលើនេះជំនាញគ្រប់គ្រងបុគ្គលិក ត្រូវទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិប្រគល់ជូន។

ជំនាញគ្រប់គ្រងបុគ្គលិក ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន អមដោយអនុប្រធានមួយចំនួន មានឋានៈស្មើ អនុប្រធាននាយកដ្ឋាន ។

**មាត្រា៧.-**

ជំនាញគ្រប់គ្រងភស្តុភារ-ហិរញ្ញវត្ថុ និងសុខាភិបាលមានតួនាទី និងភារកិច្ចដូចតទៅៈ

- មានតួនាទីជាសេនាធិការជូនមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិលើការងារធានាភស្តុភារ ហិរញ្ញវត្ថុនិងសុខាភិបាល
- លើកផែនការ ធ្វើគម្រោងថវិកាប្រចាំឆ្នាំសម្រាប់មជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ
- ធានាបើកផ្តល់ប្រាក់បៀវត្ស ប្រាក់ចំណាយផ្សេងៗ និងត្រួតពិនិត្យទូទាត់ បិទបញ្ជីផ្ទៀងផ្ទាត់
- គ្រប់គ្រង បើកចែក ស្បៀង បរិក្ខារ គ្រឿងឧបភោគ បរិភោគ ឱសថ សម្ភារៈ បរិក្ខារពេទ្យ ជូនដល់យោធិន មន្ត្រី និងបុគ្គលិកក្នុងបណ្តាស្ថាប័ន អង្គភាពចំណុះមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ
- ទំនាក់ទំនងនិងសហការជាមួយគ្រប់បណ្តាស្ថាប័ន អង្គភាពដែលពាក់ព័ន្ធការងារភស្តុភារ ហិរញ្ញវត្ថុ និងសុខាភិបាល
- ធានាថែរក្សា បើកចែកប្រេងឥន្ធនៈឱ្យសមស្របតាមក្បួនខ្នាតបច្ចេកទេស និង គោលការណ៍ដែលបានកំណត់
- តាមដាន ត្រួតពិនិត្យការប្រើប្រាស់ថវិកា សម្ភារៈ និងបរិក្ខាររបស់អង្គភាពដែលបានទទួលបានពីក្រសួង និងស្ថានប័ននានា
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ ទ្រព្យសកម្ម បញ្ជីសារពើភ័ណ្ឌ ចំណូល ចំណាយផ្សេងៗ
- លើកយោបល់បំភ្លឺអំពីការចំណាយសាច់ប្រាក់ និងគម្រោងចំណាយនានារបស់អង្គភាពពាក់ព័ន្ធដែលស្នើសុំ ជូនអគ្គនាយក មជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ ពិនិត្យ និងសម្រេច
- ធ្វើរបាយការណ៍ចំណូល ចំណាយ និងទ្រព្យសកម្ម ដើម្បីឆ្លុះបង្ហាញពីស្ថានភាព ហិរញ្ញវត្ថុរៀងរាល់ខែ ឆមាស និងប្រចាំឆ្នាំ
- បិទបញ្ជីគណនេយ្យ និងបញ្ជាក់និយ័តភាពគណនេយ្យប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- រៀបចំឯកសារ បញ្ជីស្នាមរបាយការណ៍ផ្សេងៗ ចាំបាច់សម្រាប់បង់ពន្ធអាករ និងបង់ពន្ធគយផ្សេងៗ អនុលោមទៅតាមច្បាប់ស្តីពីសារពើពន្ធ និងច្បាប់ស្តីពីគយរបស់រាជរដ្ឋាភិបាល
- ក្រៅពីភារកិច្ចខាងលើនេះជំនាញគ្រប់គ្រងភស្តុភារ ហិរញ្ញវត្ថុ និងសុខាភិបាល ត្រូវទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិប្រគល់ជូន។

ជំនាញគ្រប់គ្រងភស្តុភារ ហិរញ្ញវត្ថុ និងសុខាភិបាល ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន អមដោយអនុប្រធានមួយចំនួន មានឋានៈស្មើ អនុប្រធាននាយកដ្ឋាន ។

**មាត្រា៨.-**

ជំនាញត្រួតពិនិត្យមានតួនាទី និងភារកិច្ចដូចតទៅៈ

- មានតួនាទីជាសេនាធិការជូនមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិលើការងារត្រួតពិនិត្យ និងអង្កេតគ្រប់វិស័យក្នុងមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ
- រៀបចំវិធាន ឬលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធការងារត្រួតពិនិត្យក្នុងក្របខ័ណ្ឌជំនាញ
- ទទួលពិនិត្យ ដោះស្រាយបណ្ដឹងតវ៉ា និងវិវាទផ្សេងៗ ដែលស្ថិតក្នុងសមត្ថកិច្ចរបស់មជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ
- តាមដាន និងត្រួតពិនិត្យរាល់ការអនុវត្តច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ
- សម្របសម្រួល សហការត្រួតពិនិត្យ ជាមួយបណ្ដាអង្គភាពចំណុះមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ
- ធ្វើរបាយការណ៍ស្ដីពីសកម្មភាព និងលទ្ធផលនៃការត្រួតពិនិត្យ អង្កេតស្រាវជ្រាវ ដើម្បីរាយការណ៍ជូនអគ្គនាយកមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ
- រៀបចំ និងលើកផែនការសកម្មភាព ផែនការប្រតិបត្តិការត្រួតពិនិត្យ និងប្រតិទិនការងារ
- ធ្វើការត្រួតពិនិត្យលើនីតិវិធី បច្ចេកទេស និងការអនុវត្តកិច្ចព្រមព្រៀង ប្រព័ន្ធគ្រប់គ្រង កិច្ចសន្យា កម្មវិធី និងលក្ខណៈវិនិច្ឆ័យផ្សេងៗទៀត ដែលទាក់ទងដល់ចំណូល ចំណាយ ការប្រើប្រាស់ប្រភពធនធានរបស់មជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ
- ធ្វើការអង្កេតពិនិត្យតាមដានលើស្មារតីមនសិការរបស់យោធិន បុគ្គលិកជាវិស្វករ ជំនាញឯកទេស ជំនាញការជាតិ ជំនាញការអន្តរជាតិ មន្ត្រីជាប់កិច្ចសន្យា មន្ត្រីក្នុងមុខងារសាធារណៈ លើការគោរពវិន័យផ្ទៃក្នុង បទបញ្ជា សេចក្តីណែនាំរបស់មជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ
- សហការការងារចុះធ្វើអធិការកិច្ចជាមួយនាយកដ្ឋានអធិការកិច្ចទូទៅក្រសួងការពារជាតិ និង ក្រុមអធិការកិច្ចអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ លើស្ថាប័នជំនាញពាក់ព័ន្ធឧស្សាហកម្ម ផលិតកម្ម សិប្បកម្មក្នុងកងយោធពលខេមរភូមិន្ទ
- ក្រៅពីភារកិច្ចខាងលើនេះជំនាញត្រួតពិនិត្យ ត្រូវទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិប្រគល់ជូន។

ជំនាញត្រួតពិនិត្យ ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន អមដោយអនុប្រធានមួយចំនួន មានឋានៈស្មើ អនុប្រធាននាយកដ្ឋាន ។

**មាត្រា៩.-**

ជំនាញគ្រប់គ្រងសម្ភារៈមានតួនាទី និងភារកិច្ចដូចតទៅៈ

- មានតួនាទីជាសេនាធិការជូនមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ លើការងារគ្រប់គ្រង ទទួលបើកចែកមធ្យោបាយសម្ភារៈ ឧបករណ៍ គ្រឿងបន្លាស់ គ្រឿងចក្រ គ្រឿងបំពាក់
- មានភារកិច្ចលើការងារទទួលសម្ភារៈនានាទៅទុកដាក់ និងថែរក្សាទុកនៅក្នុងឃ្លាំង
- រៀបចំប្រព័ន្ធកិច្ចបញ្ជីការ គ្រប់គ្រងមធ្យោបាយ សម្ភារៈ ឧបករណ៍ គ្រឿងបន្លាស់ គ្រឿងចក្រ គ្រឿងបំពាក់
- កត់ត្រាបញ្ជី បញ្ចូល និងបញ្ចេញ រាល់មធ្យោបាយ សម្ភារៈ ឧបករណ៍ គ្រឿងបន្លាស់ គ្រឿងចក្រ គ្រឿងបំពាក់
- វិភាគ តាមដានកាលបរិច្ឆេទ និងសុពលភាព ប្រើប្រាស់ នូវរាល់មធ្យោបាយ សម្ភារៈ ឧបករណ៍ គ្រឿងបន្លាស់ គ្រឿងចក្រ គ្រឿងបំពាក់
- តាមដាន ណែនាំការប្រើប្រាស់ ការថែទាំ ជួសជុល

- ធ្វើរបាយការណ៍គុណភាពនូវរាល់មធ្យោបាយ សម្ភារៈ ឧបករណ៍ គ្រឿងបន្លាស់ គ្រឿងចក្រ គ្រឿងបំពាក់ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដែលយកទៅប្រើប្រាស់ក្នុងការបំពេញភារកិច្ចក្នុងមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ
- ធ្វើផែនការ និងលើកគម្រោងស្នើសុំបំពេញបន្ថែមនូវរាល់មធ្យោបាយ សម្ភារៈ ឧបករណ៍ គ្រឿងបន្លាស់ គ្រឿងចក្រ គ្រឿងបំពាក់ សម្រាប់ធានាបើកចែកសេចក្តីត្រូវការឱ្យបានទាន់ពេលវេលា
- ធ្វើការទទួលយក ធានាបើកចែករាល់មធ្យោបាយ សម្ភារៈ ឧបករណ៍ គ្រឿងបន្លាស់ គ្រឿងចក្រ គ្រឿងបំពាក់ផ្សេងៗ ជូនបណ្តាស្ថាប័ន អង្គភាពដែលស្នើសុំ
- ក្រៅពីភារកិច្ចខាងលើនេះជំនាញគ្រប់គ្រងសម្ភារៈ ត្រូវទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិប្រគល់ជូន។

ជំនាញគ្រប់គ្រងសម្ភារៈ ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន អមដោយអនុប្រធានមួយចំនួន មានឋានៈស្មើ អនុប្រធាននាយកដ្ឋាន ។

**មាត្រា១០.-**

មូលដ្ឋានតេស្តសាកល្បង និងពិសោធន៍មានតួនាទី និងភារកិច្ចដូចតទៅ៖

- មានតួនាទីជាសេនាធិការជូនមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ លើការងារតេស្តសាកល្បង និង ពិសោធន៍
- មានភារកិច្ចសហការធ្វើតេស្តសាកល្បង និងពិសោធន៍នូវរាល់គ្រប់រូបភាព និងគ្រប់ដំណាក់កាលបច្ចេកទេសឧស្សាហកម្ម ផលិតកម្ម ដោយអនុលោមទៅតាមស្តង់ដារជាតិ ស្តង់ដារអន្តរជាតិ និងស្តង់ដារឧស្សាហកម្មការពារជាតិ ប្រកបដោយគុណភាព និងសុវត្ថិភាព
- ក្រៅពីភារកិច្ចខាងលើនេះ ជំនាញគ្រប់គ្រងស្តង់ដារសម្ភារៈត្រូវទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិប្រគល់ជូន។

មូលដ្ឋានតេស្តសាកល្បង និងពិសោធន៍ ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន អមដោយអនុប្រធានមួយចំនួន មានឋានៈស្មើ អនុប្រធាននាយកដ្ឋាន ។

**មាត្រា១១.-**

នាយកដ្ឋានផែនការមានតួនាទី និងភារកិច្ចដូចតទៅ៖

- មានតួនាទីជាសេនាធិការឱ្យមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ លើការងារកសាងផែនការ សិក្សាគម្រោង អភិវឌ្ឍន៍ គ្រប់គ្រង ការអនុវត្តលើការងារស្ថិតិ និងនីតិកម្ម
- ស្រាវជ្រាវ ដកស្រង់ ចងក្រង ផ្សព្វផ្សាយ រៀបចំតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗពាក់ព័ន្ធនឹងវិស័យឧស្សាហកម្មការពារជាតិ
- កសាងផែនការ សិក្សាគម្រោង និងកំណត់ទិសដៅជាអាទិភាព ស្តីពីការអភិវឌ្ឍរយៈពេលវែង រយៈពេលមធ្យម និងរយៈពេលខ្លី ឱ្យស្របទៅតាមផែនការសេចក្តីត្រូវការរបស់កងយោធពលខេមរភូមិន្ទ
- ធ្វើការបូកសរុបរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ០៩ខែ ០១ឆ្នាំ និង០៥ឆ្នាំ របស់មជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ
- ដឹកនាំ រៀបចំ គ្រប់គ្រង អនុវត្តលើការងារចុះបញ្ជីស្ថិតិបណ្តាអង្គភាព រោងចក្រ សហគ្រាស ក្រុមហ៊ុន លើកិច្ចការឧស្សាហកម្មការពារជាតិ
- តាមដាន ត្រួតពិនិត្យ ការអនុវត្តផែនការបណ្តាគម្រោងពីគ្រប់ផ្នែកទាំងអស់ ដើម្បីវាយតម្លៃលទ្ធផលនៃការអនុវត្ត និងលើកឡើងពីវិធានការកែតម្រូវផែនការឧស្សាហកម្មការពារជាតិ
- ដឹកនាំ រៀបចំ ចាត់ចែង និងចូលរួមនូវព្រឹត្តិការណ៍នានាដែលមានការពាក់ព័ន្ធ និងការតាំងពិព័រណ៍ឧស្សាហកម្មការពារជាតិក្នុងប្រទេស និងក្រៅប្រទេស
- ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រី និងមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ អំពីការប្រព្រឹត្តទៅរបស់អង្គភាព និងសកម្មភាពឧស្សាហកម្មដែលបានអនុវត្ត

- ក្រៅពីភារកិច្ចខាងលើនេះ នាយកដ្ឋានផែនការ ត្រូវទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិប្រគល់ជូន។

នាយកដ្ឋានផែនការ ដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួន។

**មាត្រា១២.-**

នាយកដ្ឋានត្រួតពិនិត្យគុណភាព និងស្តង់ដារមានតួនាទី និងភារកិច្ចដូចតទៅ៖

- មានតួនាទីជាសេនាធិការឱ្យមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ លើការងារត្រួតពិនិត្យគុណភាពសរុប បញ្ញត្តកម្ម និងអធិការកិច្ច សិទ្ធិលើកម្មសិទ្ធិឧស្សាហកម្ម ពាណិជ្ជកម្ម តក្កកម្ម គំនូរឧស្សាហកម្ម ម៉ូដែលមានអត្ថប្រយោជន៍ និងស្តង់ដារផលិតកម្មដោយអនុលោមស្របតាមបញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីស្តង់ដារកម្ពុជា ច្បាប់ស្តីពីស្តង់ដារឧស្សហកម្មការពារជាតិ ស្របតាមគោលនយោបាយ យុទ្ធសាស្ត្រ ទិសដៅ និងផែនការរួមរបស់រាជរដ្ឋាភិបាល និងក្រសួងការពារជាតិ
- គ្រប់គ្រង រៀបចំ អនុវត្តនីតិវិធី វាយតម្លៃ ទទួលស្គាល់ និងផ្តល់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ប្រកាសនីយបត្រ តក្កកម្ម គំនូរឧស្សាហកម្ម រក្សាការសម្ងាត់ឧស្សាហកម្ម ពាណិជ្ជកម្ម និងកម្មសិទ្ធិបញ្ញា
- ដឹកនាំត្រួតពិនិត្យលក្ខណៈបច្ចេកទេស និងបច្ចេកវិទ្យាឧស្សាហកម្ម ផលិតកម្ម ដើម្បីរក្សាគុណភាព និងសុវត្ថិភាពឧស្សាហកម្ម
- រៀបចំស្តង់ដារឧស្សាហកម្មការពារជាតិ ដោយបញ្ជាក់ភាពអនុលោមតាមស្តង់ដារប្រព័ន្ធគ្រប់គ្រងផលិតកម្ម ស្តង់ដារសុវត្ថិភាព និងស្តង់ដារសម្រាប់ផលិតផលប្រភេទទំនិញ យុទ្ធោបករណ៍ អាវុធយុទ្ធភណ្ឌ គ្រាប់រំសេវ គ្រឿងចក្រ និងសម្ភារៈ ឧបករណ៍ បរិក្ខារអេឡិចត្រូនិច អគ្គិសនី និងទំនិញរួមផ្សំផ្សេងទៀត សម្រាប់ធានាដល់វិស័យការពារជាតិ ក៏ដូចជាសម្រាប់ជាប្រយោជន៍បម្រើដល់វិស័យសេវាសាធារណៈផ្សេងៗ
- កំណត់លក្ខណៈវិនិច្ឆ័យ វាយតម្លៃ ព្យួរទុក ដកហូត និងលុបចោលអាជ្ញាប័ណ្ណប្រើសញ្ញាស្តង់ដារបញ្ជាក់ផលិតផល ឬវិញ្ញាបនបត្របញ្ជាក់ភាពអនុលោមផលិតផល ឬវិញ្ញាបនបត្រចុះបញ្ជីផលិតផល ឬវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធគ្រប់គ្រងផលិតកម្ម
- វាយតម្លៃ ទទួលស្គាល់អង្គភាពចេញវិញ្ញាបនបត្រ ប្រកាសនីយបត្រ មន្ទីរពិសោធន៍ និងឧបករណ៍ផ្សេងទៀតរបស់អង្គភាពក្នុង និងក្រៅប្រទេស ដែលមានកម្មវត្ថុ និងគោលបំណងដោយអនុលោមស្របតាមវិស័យឧស្សាហកម្មការពារជាតិ
- សហការណ៍ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ លើការត្រួតពិនិត្យបទល្មើសក្នុងការផលិត និងតម្លើងផលិតផលពាក់ព័ន្ធនឹងវិស័យឧស្សាហកម្មការពារជាតិ
- ក្រៅពីភារកិច្ចខាងលើនេះនាយកដ្ឋានត្រួតពិនិត្យគុណភាព និងស្តង់ដារ ត្រូវទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិប្រគល់ជូន។

នាយកដ្ឋានត្រួតពិនិត្យគុណភាព និងស្តង់ដារ ដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួន។

**មាត្រា១៣.-**

នាយកដ្ឋានសហប្រតិបត្តិការឧស្សាហកម្មយោធា-ស៊ីវិល មានតួនាទី និងភារកិច្ចដូចតទៅ៖

- មានតួនាទីជាសេនាធិការឱ្យមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ លើការងាររៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសហប្រតិបត្តិការវិនិយោគ ក្នុងវិស័យឧស្សាហកម្មការពារជាតិ ដើម្បីគៀងគរធនធាន បង្កប្រភព សេដ្ឋកិច្ច ហិរញ្ញវត្ថុ ពាណិជ្ជកម្ម វិនិយោគ ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល
- រៀបចំកិច្ចព្រមព្រៀង អនុស្សារណៈ និងគោលនយោបាយវិនិយោគ ពាណិជ្ជកម្មប្រកបដោយតម្លាភាព
- ដឹកនាំ គ្រប់គ្រង ចាត់ចែង សិក្សាស្រាវជ្រាវ លើគម្រោងវិនិយោគ បង្កប្រភពវិនិយោគដោយផ្ទាល់ វិនិយោគដោយប្រយោល ឬវិនិយោគដោយផ្នែក ដើម្បីស្វែងរកការគាំទ្រពីដៃគូអភិវឌ្ឍន៍នានា

- សហប្រតិបត្តិការ និងចូលរួមជាមួយបណ្តាប្រទេស ស្ថាប័ន សហគ្រាស រោងចក្រ ក្រុមហ៊ុនជាតិ និងអន្តរជាតិនានា ដើម្បីរួមគ្នាជួយជ្រោមជ្រែង ជម្រុញការកសាងបណ្តាញវិនិយោគ និងអភិវឌ្ឍន៍វិស័យឧស្សាហកម្មការពារជាតិ
- លើកសំណើ សម្របសម្រួល និងពិនិត្យតាមដានការអនុវត្តគោលនយោបាយវិនិយោគ ដែលពាក់ព័ន្ធវិស័យឧស្សាហកម្មការពារជាតិ
- កសាងទំនាក់ទំនង ផ្លាស់ប្តូរ និងជម្រុញការវិនិយោគ កិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម ឧស្សាហកម្មការពារជាតិ ដែលជាលក្ខខណ្ឌអំណោយផលមួយ ក្នុងការទទួលបាននូវព័ត៌មាន ទិន្នន័យ និងការផ្ទេរនូវចំណេះដឹង បទពិសោធន៍ និងការផ្ទេរជំនាញបច្ចេកវិទ្យាឧស្សាហកម្ម
- កសាង ដឹកនាំ គម្រោងផែនការនាំចេញ នាំចូលនូវវត្ថុធាតុដើម គ្រឿងបន្លាស់ គ្រឿងបង្គុំ សមាសធាតុផ្សំ សារធាតុ សម្ភារៈ ឧបករណ៍នានា សម្រាប់ធានាប្រើប្រាស់ក្នុងវិស័យឧស្សាហកម្មការពារជាតិ
- កសាង ដឹកនាំ ធ្វើទីផ្សារនាំចេញ នាំចូល នូវផលិតផលសម្រេច ឬផលិតផលពាក់កណ្តាលសម្រេច គ្រឿងបន្លាស់ គ្រឿងបង្គុំ សមាសធាតុផ្សំ សារធាតុ សម្ភារៈ ឧបករណ៍នានា ស្របទៅតាមគម្រោងផែនការធានារបស់កងយោធពល-ខេមរភូមិន្ទ
- រៀបចំ ចាត់ចែង និងចូលរួមនូវរាល់ព្រឹត្តិការណ៍ទាំងឡាយពាក់ព័ន្ធនឹងការផ្សព្វផ្សាយ ជម្រុញការអភិវឌ្ឍឧស្សាហកម្មការពារជាតិ
- លើកស្ទួយសង្វាក់ផលិតកម្ម សក្តានុពលក្នុងវិស័យធុរកិច្ច និងវិនិយោគសកល កសាងទំនុកចិត្តផ្នែកទីផ្សារ និងបង្កើនទំហំពាណិជ្ជកម្ម
- ក្រៅពីភារកិច្ចខាងលើនេះ នាយកដ្ឋានសហប្រតិបត្តិការឧស្សាហកម្មយោធាស៊ីវិល- ត្រូវទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិប្រគល់ជូន។

នាយកដ្ឋានសហប្រតិបត្តិការឧស្សាហកម្មយោធា-ស៊ីវិល ដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួន។

**មាត្រា១៤.-**

សហគ្រាសអាវុធថ្មើរជើងមានតួនាទី និងភារកិច្ចដូចតទៅ៖

- មានតួនាទីជាសេនាធិការឱ្យមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ លើការងារឧស្សាហកម្ម ផលិតកម្មអាវុធថ្មើរជើង គ្រប់ចុន និងគ្រាប់ថ្មើរជើងគ្រប់ប្រភេទ សម្រាប់ធានាដល់វិស័យការពារជាតិ
- ធ្វើទំនើបកម្ម រចនា កែច្នៃ អភិវឌ្ឍន៍ ផលិតអាវុធថ្មើរជើងគ្រប់ចុន និងគ្រាប់ថ្មើរជើងគ្រប់ប្រភេទ ស្របតាមស្តង់ដារផលិតកម្ម និងបទដ្ឋានបច្ចេកទេស ដោយគោរពតាមផែនការរបស់ក្រសួងការពារជាតិ
- ធ្វើជាអាណាព្យាបាល រៀបចំ ដឹកនាំ ត្រួតពិនិត្យ និងសម្របសម្រួលបណ្តាសហគ្រាស រោងចក្រ ក្រុមហ៊ុន ផលិតអាវុធ និងគ្រាប់ថ្មើរជើងទាំងអស់ដែលពាក់ព័ន្ធឧស្សាហកម្មការពារជាតិ
- ស្រាវជ្រាវ ធ្វើតេស្ត វិភាគ និងពិសោធន៍រកឱ្យឃើញនូវរបកគំហើញថ្មីៗ ដើម្បីជម្រុញការអភិវឌ្ឍឧស្សាហកម្មអាវុធថ្មើរជើង និងគ្រាប់ថ្មើរជើងស្របតាមការវិវឌ្ឍវិស័យយោធារបស់សកលលោក
- កំណត់លក្ខណៈវិនិច្ឆ័យ វាយតម្លៃ និងទទួលស្គាល់ប្រសិទ្ធភាព បរិមាណ គុណភាព និងលក្ខណៈសម្បត្តិអាវុធថ្មើរជើង និងគ្រាប់ថ្មើរជើងដែលបានផលិតរួចរាល់
- សហការណ៍ជាមួយបណ្តាស្ថាប័នជាតិ និងអន្តរជាតិទាំងក្នុង និងក្រៅប្រទេស លើការងារឧស្សាហកម្មផលិតអាវុធថ្មើរជើង និងគ្រាប់ថ្មើរជើង
- លើកគម្រោងផែនការហ្វឹកហ្វឺន និងបណ្តុះបណ្តាលជំនាញឯកទេស លើការងារឧស្សាហកម្មផលិតអាវុធថ្មើរជើង និងគ្រាប់ថ្មើរជើង

- ក្រៅពីភារកិច្ចខាងលើនេះសហគ្រាសអាវុធថ្មើរជើង ត្រូវទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិប្រគល់ជូន។

សហគ្រាសអាវុធថ្មើរជើង ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន អមដោយអនុប្រធានមួយចំនួន មានឋានៈស្មើអនុប្រធាននាយកដ្ឋាន។

**មាត្រា១៥.-**

សហគ្រាសកាំភ្លើងផ្ទៃដីមានតួនាទី និងភារកិច្ចដូចតទៅៈ

- មានតួនាទីជាសេនាធិការឱ្យមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ លើការងារឧស្សាហកម្ម ផលិតកម្មកាំភ្លើងធំគ្រប់ធុន កាំភ្លើងប្រឆាំងរថក្រោះគ្រប់ធុន កាំភ្លើងផ្ទៃដីការពារអាកាស គ្រាប់កាំភ្លើងធំ គ្រាប់កាំភ្លើងប្រឆាំងរថក្រោះ គ្រាប់កាំភ្លើងការពារអាកាស និងគ្រាប់អាវុធគ្រប់ប្រភេទ សម្រាប់ធានាដល់វិស័យការពារជាតិ
- ធ្វើទំនើបកម្ម រចនា កែច្នៃ អភិវឌ្ឍន៍ ផលិតកាំភ្លើងធំគ្រប់ធុន កាំភ្លើងប្រឆាំងរថក្រោះគ្រប់ធុន និងកាំភ្លើងផ្ទៃដីការពារអាកាស គ្រាប់កាំភ្លើងធំ គ្រាប់កាំភ្លើងប្រឆាំងរថក្រោះ គ្រាប់កាំភ្លើងការពារអាកាស និងគ្រាប់អាវុធគ្រប់ប្រភេទ ស្របតាមស្តង់ដារផលិតកម្ម និងបទដ្ឋានបច្ចេកទេស ដោយគោរពតាមផែនការរបស់ក្រសួងការពារជាតិ
- ធ្វើជាអាណាព្យាបាល រៀបចំ ដឹកនាំ ត្រួតពិនិត្យ និងសម្របសម្រួលបណ្តាសហគ្រាស រោងចក្រ ក្រុមហ៊ុនផលិតកាំភ្លើងធំគ្រប់ធុន គ្រាប់កាំភ្លើងប្រឆាំងរថក្រោះ កាំភ្លើងផ្ទៃដីការពារអាកាស គ្រាប់កាំភ្លើងធំ គ្រាប់កាំភ្លើងប្រឆាំងរថក្រោះ កាំភ្លើងការពារអាកាស និងគ្រាប់អាវុធគ្រប់ប្រភេទទាំងអស់ ដែលពាក់ព័ន្ធឧស្សាហកម្មការពារជាតិ
- ស្រាវជ្រាវ ធ្វើតេស្ត វិភាគ និងពិសោធន៍រកឱ្យឃើញនូវរបកគំហើញថ្មីៗ ដើម្បីជម្រុញការអភិវឌ្ឍន៍ឧស្សាហកម្មកាំភ្លើងធំគ្រប់ធុន គ្រាប់កាំភ្លើងប្រឆាំងរថក្រោះ កាំភ្លើងផ្ទៃដីការពារអាកាស គ្រាប់កាំភ្លើងធំ គ្រាប់កាំភ្លើងប្រឆាំងរថក្រោះ កាំភ្លើងការពារអាកាស និងគ្រាប់អាវុធគ្រប់ប្រភេទ ស្របតាមការវិវឌ្ឍវិស័យយោធារបស់សកលលោក
- កំណត់លក្ខណៈវិនិច្ឆ័យ វាយតម្លៃ និងទទួលស្គាល់ប្រសិទ្ធភាព បរិមាណ គុណភាព និងលក្ខណៈសម្បត្តិកាំភ្លើងធំគ្រប់ធុន គ្រាប់កាំភ្លើងប្រឆាំងរថក្រោះ កាំភ្លើងផ្ទៃដីការពារអាកាស គ្រាប់កាំភ្លើងធំ គ្រាប់កាំភ្លើងប្រឆាំងរថក្រោះ កាំភ្លើងការពារអាកាស និងគ្រាប់អាវុធគ្រប់ប្រភេទ ដែលបានផលិតរួចរាល់
- សហការណ៍ជាមួយបណ្តាស្ថាប័នជាតិ និងអន្តរជាតិទាំងក្នុង និងក្រៅប្រទេស លើការងារឧស្សាហកម្មផលិតកាំភ្លើងធំគ្រប់ធុន គ្រាប់កាំភ្លើងប្រឆាំងរថក្រោះ កាំភ្លើងផ្ទៃដីការពារអាកាស គ្រាប់កាំភ្លើងធំ គ្រាប់កាំភ្លើងប្រឆាំងរថក្រោះ កាំភ្លើងការពារអាកាស និងគ្រាប់អាវុធគ្រប់ប្រភេទ
- លើកគម្រោងផែនការហ្វឹកហ្វឺន និងបណ្តុះបណ្តាលជំនាញឯកទេស លើការងារឧស្សាហកម្មផលិតកាំភ្លើងធំគ្រប់ធុន គ្រាប់កាំភ្លើងប្រឆាំងរថក្រោះ កាំភ្លើងផ្ទៃដីការពារអាកាស គ្រាប់កាំភ្លើងធំ គ្រាប់កាំភ្លើងប្រឆាំងរថក្រោះ កាំភ្លើងការពារអាកាស និងគ្រាប់អាវុធគ្រប់ប្រភេទ
- ក្រៅពីភារកិច្ចខាងលើនេះសហគ្រាសកាំភ្លើងផ្លោងផ្ទៃដី ត្រូវទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិប្រគល់ជូន។

សហគ្រាសកាំភ្លើងផ្ទៃដី ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន អមដោយអនុប្រធានមួយចំនួន មានឋានៈស្មើ អនុប្រធាននាយកដ្ឋាន។

**មាត្រា១៦.-**

សហគ្រាសផលិតកម្មគីមីសាស្ត្រមានតួនាទី និងភារកិច្ចដូចតទៅៈ

- មានតួនាទីជាសេនាធិការឱ្យមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ លើការងារឧស្សាហកម្មផលិតកម្មនូវរាល់ឧបករណ៍ សម្ភារៈ សារធាតុគីមីសាស្ត្រ ជីវសាស្ត្រ និងពិសោធន៍ អភិវឌ្ឍន៍នូវរបក គំហើញថ្មីៗ សម្រាប់ធានាដល់វិស័យឧស្សាហកម្មការពារជាតិ

- ធ្វើទំនើបកម្ម រចនា កែច្នៃ អភិវឌ្ឍន៍ និងផលិតនូវរាល់ឧបករណ៍ សម្ភារៈគីមីសាស្ត្រ ជីវសាស្ត្រ ស្របតាមស្តង់ដារផលិតកម្ម និងបទដ្ឋានបច្ចេកទេស ក្នុងគោលដៅប្រើប្រាស់ក្នុងវិស័យឧស្សាហកម្មការពារជាតិ ឧស្សាហកម្មរ៉ែថាមពល វិស័យសុខាភិបាល កសិកម្ម ស្រាវជ្រាវ និងបម្រុងទុកសម្រាប់ជាប្រយោជន៍ធានាការពារ ទប់ស្កាត់ពេលមានសង្គ្រាមកើតឡើង និងគោលដៅផ្សេងទៀតដែលមានការអនុញ្ញាត ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច និងផលិតដោយអនុលោមទៅតាមច្បាប់ជាតិ និងអន្តរជាតិ សន្ធិសញ្ញា កតិកាសញ្ញា អនុសញ្ញា របស់អង្គការសហប្រជាជាតិ
- ធ្វើជាអាណាព្យាបាល រៀបចំ ដឹកនាំ ត្រួតពិនិត្យ និងសម្របសម្រួលបណ្តាសហគ្រាស រោងចក្រ ក្រុមហ៊ុន ផលិតកម្មគីមីសាស្ត្រ ជីវសាស្ត្រ ដែលពាក់ព័ន្ធឧស្សាហកម្មការពារជាតិ
- ធ្វើតេស្ត វិភាគនិងពិសោធន៍រកឱ្យឃើញនូវរបកគំហើញថ្មីៗ ដើម្បីធានាដល់ការផលិតនូវឧបករណ៍ សម្ភារៈគីមីសាស្ត្រ ជីវសាស្ត្រ និងសារធាតុគីមីសាស្ត្រ
- រៀបចំ និងគ្រប់គ្រងស្តង់ដារ និងបញ្ជាក់មុខសញ្ញាសារធាតុគីមីប្រើប្រាស់ក្នុងសហគ្រាសគីមីសាស្ត្រ និងសហគ្រាសដទៃទៀត
- កំណត់លក្ខណៈវិនិច្ឆ័យផលិតផលគីមីសាស្ត្រ ជីវសាស្ត្រ និងសារធាតុគីមីសាស្ត្រ ក្នុងវិស័យឧស្សាហកម្មការពារជាតិ
- សហការណ៍ជាមួយបណ្តាស្ថាប័នជាតិ និងអន្តរជាតិទាំងក្នុង និងក្រៅប្រទេស លើការងារឧស្សាហកម្ម គីមីសាស្ត្រ និងជីវសាស្ត្រ
- លើកគម្រោងផែនការហ្វឹកហ្វឺន និងបណ្តុះបណ្តាលជំនាញឯកទេស លើការងារឧស្សាហកម្មគីមីសាស្ត្រ និងជីវសាស្ត្រ
- ក្រៅពីភារកិច្ចខាងលើនេះសហគ្រាសគីមីសាស្ត្រ ត្រូវទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិប្រគល់ជូន។

សហគ្រាសផលិតកម្មគីមីសាស្ត្រ ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន អមដោយអនុប្រធានមួយចំនួន មានឋានៈស្មើ អនុប្រធាននាយកដ្ឋាន។

**មាត្រា១៧.-**

សហគ្រាសយានយន្តមានតួនាទី និងភារកិច្ចដូចតទៅ៖

- មានតួនាទីជាសេនាធិការឱ្យមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ លើការងារផលិត និងតម្លើងយានយន្ត ទោចក្រយានយន្ត កង់ អាគុយ គ្រឿងចក្រគ្រប់ប្រភេទសម្រាប់ធានាដល់វិស័យការពារជាតិ
- ធ្វើទំនើបកម្ម រចនា កែច្នៃ អភិវឌ្ឍន៍ ផលិត និងតម្លើងយានយន្តធុនតូច យានយន្តធុនធ្ងន់ យានយន្តដឹកជញ្ជូន គ្រឿងចក្រវិស្វកម្ម គ្រឿងចក្រសាងសង់ គ្រឿងចក្រកសិកម្មគ្រប់ប្រភេទ ផលិតនិងតម្លើងទោចក្រយានយន្ត ផលិត និងតម្លើងកង់ ផលិតសំបកកង់ និងអាគុយសម្រាប់ធានាដល់ប្រតិបត្តិការសឹក ស្របតាមស្តង់ដារផលិតកម្ម និងបទដ្ឋានបច្ចេកទេសដោយគោរពតាមផែនការរបស់ក្រសួងការពារជាតិ
- ធ្វើជាអាណាព្យាបាល រៀបចំ ដឹកនាំ ត្រួតពិនិត្យ និងសម្របសម្រួលបណ្តាសហគ្រាស រោងចក្រ ក្រុមហ៊ុន ផលិត និងតម្លើងយានយន្តធុនតូច យានយន្តធុនធ្ងន់ យានយន្តដឹកជញ្ជូន គ្រឿងចក្រវិស្វកម្ម គ្រឿងចក្រសាងសង់ គ្រឿងចក្រកសិកម្មគ្រប់ប្រភេទ ផលិតនិងតម្លើងទោចក្រយានយន្ត ផលិត និងតម្លើងកង់ ផលិតសំបកកង់ និងអាគុយគ្រប់ប្រភេទ
- ស្រាវជ្រាវ ធ្វើតេស្ត វិភាគ និងពិសោធន៍រកឱ្យឃើញនូវរបកគំហើញថ្មីៗ ដើម្បីជម្រុញការអភិវឌ្ឍ ឧស្សាហកម្ម ផលិតនិងតម្លើងយានយន្តធុនតូច យានយន្តធុនធ្ងន់ យានយន្តដឹកជញ្ជូន គ្រឿងចក្រវិស្វកម្ម គ្រឿងចក្រសាងសង់ គ្រឿងចក្រកសិកម្មគ្រប់ប្រភេទ ផលិតនិងតម្លើងទោចក្រយានយន្ត ផលិតនិង តម្លើងកង់ ផលិតសំបកកង់ និងអាគុយស្របតាមការវិវឌ្ឍវិស័យយោធារបស់សកលលោក
- កំណត់លក្ខណៈវិនិច្ឆ័យ វាយតម្លៃ និងទទួលស្គាល់ប្រសិទ្ធភាព បរិមាណ គុណភាព និងលក្ខណៈសម្បត្តិផលិតផលដែលបានផលិតនិងតម្លើងរួចរាល់

- សហការណ៍ជាមួយបណ្តាស្ថាប័នជាតិ និងអន្តរជាតិទាំងក្នុង និងក្រៅប្រទេស លើការងារផលិត និងតម្លើងយានយន្តធុនតូច យានយន្តធុនធ្ងន់ យានយន្តដឹកជញ្ជូន គ្រឿងចក្រវិស្វកម្ម គ្រឿងចក្រ សាងសង់ គ្រឿងចក្រកសិកម្មគ្រប់ប្រភេទ ផលិត និងតម្លើងទោចក្រយានយន្ត ផលិត និងតម្លើងកង់ ផលិតសំបកកង់ និងអាគុយ
- លើកគម្រោងផែនការហ្វឹកហ្វឺន និងបណ្តុះបណ្តាលជំនាញឯកទេស លើការងារឧស្សាហកម្ម ផលិតនិងតម្លើងយានយន្តធុនតូច យានយន្តធុនធ្ងន់ យានយន្តដឹកជញ្ជូន គ្រឿងចក្រវិស្វកម្ម គ្រឿងចក្រសាងសង់ គ្រឿងចក្រកសិកម្មគ្រប់ប្រភេទ ផលិត និងតម្លើងទោចក្រយានយន្ត ផលិតនិងតម្លើងកង់ ផលិតសំបកកង់ និងអាគុយ
- ក្រៅពីភារកិច្ចខាងលើនេះសហគ្រាសយានយន្ត ត្រូវទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិប្រគល់ជូន។

សហគ្រាសយានយន្ត ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន អមដោយអនុប្រធានមួយចំនួន មានឋានៈស្មើ អនុប្រធាននាយកដ្ឋាន។

**មាត្រា១៨.-**

សហគ្រាសផលិតគ្រឿងអេឡិចត្រូនិចមានតួនាទី និងភារកិច្ចដូចតទៅៈ

- មានតួនាទីជាសេនាធិការឱ្យមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ លើការងារឧស្សាហកម្ម ផលិតនិងតម្លើងកែវឆ្លុះ ឧបករណ៍អេឡិចត្រូនិចនាំផ្លូវដោយផ្កាយរណប រ៉ាដា វិទ្យុទាក់ទង ទូរស័ព្ទ បរិក្ខារគ្រជាក់ និងខ្សែអុបទិចគ្រប់ប្រភេទសម្រាប់បម្រើវិស័យការពារជាតិ វិស័យសេវាសាធារណៈ និងវិស័យ ទូរគមនាគមន៍
- ធ្វើទំនើបកម្ម រចនា កែច្នៃ អភិវឌ្ឍន៍ ផលិតនិងតម្លើងកែវឆ្លុះ ឧបករណ៍អេឡិចត្រូនិចនាំផ្លូវដោយផ្កាយរណប រ៉ាដា វិទ្យុទាក់ទង ទូរស័ព្ទ បរិក្ខារគ្រជាក់ និងខ្សែអុបទិចគ្រប់ប្រភេទ ស្របតាមស្តង់ដារផលិតកម្ម និងបទដ្ឋានបច្ចេកទេសដោយគោរពតាមផែនការរបស់ក្រសួងការពារជាតិ
- ធ្វើជាអាណាព្យាបាល រៀបចំ ដឹកនាំ ត្រួតពិនិត្យ និងសម្របសម្រួលបណ្តាសហគ្រាស រោងចក្រ ក្រុមហ៊ុន ផលិតនិងតម្លើងកែវឆ្លុះ ឧបករណ៍អេឡិចត្រូនិចនាំផ្លូវដោយផ្កាយរណប រ៉ាដា វិទ្យុទាក់ទង ទូរស័ព្ទ បរិក្ខារគ្រជាក់ និងខ្សែអុបទិចគ្រប់ប្រភេទទាំងអស់ដែលពាក់ព័ន្ធឧស្សាហកម្មការពារជាតិ
- ស្រាវជ្រាវ ធ្វើតេស្ត វិភាគ និងពិសោធន៍រកឱ្យឃើញនូវរបកគំហើញថ្មីៗ ដើម្បីជម្រុញការអភិវឌ្ឍ ឧស្សាហកម្ម ផលិតនិងតម្លើងកែវឆ្លុះ ឧបករណ៍អេឡិចត្រូនិចនាំផ្លូវដោយផ្កាយរណប រ៉ាដា វិទ្យុទាក់ទង ទូរស័ព្ទ បរិក្ខារគ្រជាក់ និងខ្សែអុបទិចគ្រប់ប្រភេទ ស្របតាមការវិវឌ្ឍវិស័យយោធារបស់សកលលោក
- កំណត់លក្ខណៈវិនិច្ឆ័យ វាយតម្លៃ និងទទួលស្គាល់ប្រសិទ្ធភាព បរិមាណ គុណភាព និងលក្ខណៈសម្បត្តិផលិតផលកែវឆ្លុះ ឧបករណ៍អេឡិចត្រូនិចនាំផ្លូវដោយផ្កាយរណប រ៉ាដា វិទ្យុទាក់ទងទូរស័ព្ទ បរិក្ខារគ្រជាក់ និង ខ្សែអុបទិចគ្រប់ប្រភេទដែលបានផលិត និងតម្លើងរួចរាល់
- សហការណ៍ជាមួយបណ្តាស្ថាប័នជាតិ និងអន្តរជាតិទាំងក្នុង និងក្រៅប្រទេស លើការងារឧស្សាហកម្ម ផលិតនិងតម្លើងកែវឆ្លុះ ឧបករណ៍អេឡិចត្រូនិចនាំផ្លូវដោយផ្កាយរណប រ៉ាដា វិទ្យុទាក់ទង ទូរស័ព្ទ បរិក្ខារគ្រជាក់ និងខ្សែអុបទិចគ្រប់ប្រភេទ
- លើកគម្រោងផែនការហ្វឹកហ្វឺន និងបណ្តុះបណ្តាលជំនាញឯកទេស លើការងារឧស្សាហកម្ម ផលិតនិងតម្លើងកែវឆ្លុះ ឧបករណ៍អេឡិចត្រូនិចនាំផ្លូវដោយផ្កាយរណប រ៉ាដា វិទ្យុទាក់ទង ទូរស័ព្ទ បរិក្ខារគ្រជាក់ និងខ្សែអុបទិចគ្រប់ប្រភេទ
- ក្រៅពីភារកិច្ចខាងលើនេះសហគ្រាសផលិតគ្រឿងអេឡិចត្រូនិច ត្រូវទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិប្រគល់ជូន។

សហគ្រាសផលិតគ្រឿងអេឡិចត្រូនិច ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន អមដោយអនុប្រធានមួយចំនួន មានឋានៈស្មើ អនុប្រធាននាយកដ្ឋាន។

**មាត្រា១៩.-**

សហគ្រាសរំសេវផ្ទុះមានតួនាទី និងភារកិច្ចដូចតទៅ៖

- កំណត់ចេញនូវទិសដៅ គោលនយោបាយ ច្បាប់ បទដ្ឋាននៃវិស័យផលិតរំសេវផ្ទុះ និងគ្រឿងគួបផ្សំ បម្រើការបំផ្ទុះ
- រៀបចំ ចាត់ចែង និងគ្រប់គ្រងឱ្យបានហ្មត់ចត់លើការផលិត និងចែកចាយ
- សិក្សា និងកំណត់ចេញផែនការប្រចាំឆ្នាំសម្រាប់ការពិសោធន៍ ការផលិត ការវិនិយោគ និងការប្រើប្រាស់ទុនវិនិយោគ
- ទទួលខុសត្រូវ និងរៀបចំការងារទំនាក់ទំនង និងសហការជាមួយវិនិយោគិន
- ការបង្កើនសមត្ថភាពក្នុងការផលិត ផ្គត់ផ្គង់ឱ្យបានល្អប្រសើរ
- ដឹកនាំវិស័យផលិតកម្មលើវិស័យរំសេវផ្ទុះ និងកាំជ្រួចបាញ់លម្អគ្រប់ប្រភេទ ធានាទាំងបរិមាន និងគុណភាព
- គ្រប់គ្រងធានាឱ្យបានសុវត្ថិភាពតាមបណ្តារោងចក្រ ជៀសវាងការឆេះ ឬបាត់បង់
- ពង្រឹង ពង្រីកសមត្ថភាពអ្នកបច្ចេកទេសបន្ថែម ដើម្បីធានាបានលើគុណភាពផលិតផល
- ក្រៅពីភារកិច្ចខាងលើនេះសហគ្រាសរំសេវផ្ទុះ ត្រូវទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិប្រគល់ជូន។

សហគ្រាសរំសេវផ្ទុះ ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន អមដោយអនុប្រធានមួយចំនួន មានឋានៈស្មើ អនុប្រធាននាយកដ្ឋាន។

**មាត្រា២០.-**

សហគ្រាសយន្តសាស្ត្រមានតួនាទី និងភារកិច្ចដូចតទៅ៖

- មានតួនាទីជាសេនាធិការឱ្យមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ លើការងារផលិត ម៉ាស៊ីន គ្រឿងយន្ត គ្រឿងបន្លាស់ និងក្រឡឹងទូទៅគ្រប់ប្រភេទសម្រាប់ធានាដល់វិស័យការពារជាតិ
- ធ្វើទំនើបកម្ម រចនា កែច្នៃ អភិវឌ្ឍន៍ផលិតម៉ាស៊ីន គ្រឿងយន្ត គ្រឿងបន្លាស់ និងក្រឡឹងទូទៅគ្រប់ប្រភេទសម្រាប់ធានាដល់ប្រតិបត្តិការសឹក ស្របតាមស្តង់ដារផលិតកម្ម និងបទដ្ឋានបច្ចេកទេសដោយគោរពតាមផែនការរបស់ក្រសួងការពារជាតិ
- ធ្វើជាអាណាព្យាបាល រៀបចំ ដឹកនាំ ត្រួតពិនិត្យ និងសម្របសម្រួលបណ្តាសហគ្រាស រោងចក្រ ក្រុមហ៊ុនផលិតម៉ាស៊ីន គ្រឿងយន្ត គ្រឿងបន្លាស់ និងក្រឡឹងទូទៅគ្រប់ប្រភេទទាំងអស់ដែលពាក់ព័ន្ធឧស្សាហកម្មការពារជាតិ
- ស្រាវជ្រាវ ធ្វើតេស្ត វិភាគ និងពិសោធន៍រកឱ្យឃើញនូវរបកគំហើញថ្មីៗ ដើម្បីជម្រុញការអភិវឌ្ឍ ឧស្សាហកម្មផលិតម៉ាស៊ីន គ្រឿងយន្ត គ្រឿងបន្លាស់ និងក្រឡឹងទូទៅគ្រប់ប្រភេទ ស្របតាមការ វិវឌ្ឍវិស័យយោធារបស់សកលលោក
- កំណត់លក្ខណៈវិនិច្ឆ័យ វាយតម្លៃ និងទទួលស្គាល់ប្រសិទ្ធភាព បរិមាណ គុណភាព និងលក្ខណៈសម្បត្តិ ផលិតផលម៉ាស៊ីន គ្រឿងយន្ត គ្រឿងបន្លាស់ និងក្រឡឹងទូទៅគ្រប់ប្រភេទដែលបានផលិតរួចរាល់
- សហការណ៍ជាមួយបណ្តាស្ថាប័នជាតិ និងអន្តរជាតិទាំងក្នុង និងក្រៅប្រទេស លើការងារឧស្សាហកម្មផលិតម៉ាស៊ីន គ្រឿងយន្ត គ្រឿងបន្លាស់ និងក្រឡឹងទូទៅគ្រប់ប្រភេទ
- លើកគម្រោងផែនការហ្វឹកហ្វឺន និងបណ្តុះបណ្តាលជំនាញឯកទេស លើការងារឧស្សាហកម្មផលិតម៉ាស៊ីន គ្រឿងយន្ត គ្រឿងបន្លាស់ និងក្រឡឹងទូទៅគ្រប់ប្រភេទ
- ក្រៅពីភារកិច្ចខាងលើនេះសហគ្រាសយន្តសាស្ត្រ ត្រូវទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិប្រគល់ជូន។

សហគ្រាសយន្តសាស្ត្រ ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន អមដោយអនុប្រធានមួយចំនួន មានឋានៈស្មើ អនុប្រធាននាយកដ្ឋាន។

**មាត្រា២១.-**

សហគ្រាសផលិតអាវុធការពារអាកាសមានតួនាទី និងភារកិច្ចដូចតទៅ៖

- មានតួនាទីជាសេនាធិការឱ្យមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ លើការងារឧស្សាហកម្ម ផលិតកម្មកាំភ្លើងលើលើស្មារការពារអាកាស កាំជ្រួចការពារអាកាស កាំភ្លើងកាំរស្មីឡាស៊ែរការពារអាកាស ដ្រូនស៊ើបការណ៍ ដ្រូនប្រយុទ្ធ ដ្រូនពិឃាត និងដ្រូនដឹកជញ្ជូន សម្រាប់ធានាដល់វិស័យការពារជាតិ
- ធ្វើទំនើបកម្ម រចនា កែច្នៃ អភិវឌ្ឍន៍ កាំភ្លើងលើលើស្មារការពារអាកាស កាំជ្រួចការពារអាកាស កាំភ្លើង កាំរស្មីឡាស៊ែរការពារអាកាស ដ្រូនស៊ើបការណ៍ ដ្រូនប្រយុទ្ធ ដ្រូនពិឃាត និងដ្រូនដឹកជញ្ជូន ស្របតាមស្តង់ដារផលិតកម្ម និងបទដ្ឋានបច្ចេកទេសដោយគោរពតាមផែនការរបស់ក្រសួងការពារជាតិ
- ធ្វើជាអាណាព្យាបាល រៀបចំ ដឹកនាំ ត្រួតពិនិត្យ និងសម្របសម្រួលបណ្តាសហគ្រាស រោងចក្រ ក្រុមហ៊ុន កាំភ្លើងលើលើស្មារការពារអាកាស កាំជ្រួចការពារអាកាស កាំភ្លើងកាំរស្មីឡាស៊ែរការពារអាកាស ដ្រូនស៊ើបការណ៍ ដ្រូនប្រយុទ្ធ ដ្រូនពិឃាត និងដ្រូនដឹកជញ្ជូនទាំងអស់ដែលពាក់ព័ន្ធឧស្សាហកម្មការពារជាតិ
- ស្រាវជ្រាវ ធ្វើតេស្ត វិភាគ និងពិសោធន៍រកឱ្យឃើញនូវរបកគំហើញថ្មីៗ ដើម្បីជម្រុញការអភិវឌ្ឍ ឧស្សាហកម្មកាំភ្លើងការពារអាកាសបំពាក់លើយានគ្រប់ប្រភេទ កាំភ្លើងលើលើស្មារការពារអាកាស កាំជ្រួចការពារអាកាស កាំភ្លើងកាំរស្មីឡាស៊ែរការពារអាកាស ដ្រូនស៊ើបការណ៍ ដ្រូនប្រយុទ្ធ ដ្រូនពិឃាត និងដ្រូនដឹកជញ្ជូនស្របតាមការវិវឌ្ឍវិស័យយោធារបស់សកលលោក
- កំណត់លក្ខណៈវិនិច្ឆ័យ វាយតម្លៃ និងទទួលស្គាល់ប្រសិទ្ធភាព បរិមាណ គុណភាព និងលក្ខណៈសម្បត្តិកាំភ្លើងការពារអាកាស កាំភ្លើងលើលើស្មារការពារអាកាស កាំជ្រួចការពារអាកាស កាំភ្លើងកាំរស្មីឡាស៊ែរការពារអាកាស ដ្រូនស៊ើបការណ៍ ដ្រូនប្រយុទ្ធ ដ្រូនពិឃាត និងដ្រូនដឹកជញ្ជូនដែលបានផលិត និងតម្លើងរួចរាល់
- សហការណ៍ជាមួយបណ្តាស្ថាប័នជាតិ និងអន្តរជាតិទាំងក្នុង និងក្រៅប្រទេស លើការងារឧស្សាហកម្មផលិតកាំភ្លើងការពារអាកាស កាំភ្លើងលើលើស្មារការពារអាកាស កាំជ្រួចការពារអាកាស កាំភ្លើងកាំរស្មីឡាស៊ែរការពារអាកាស ដ្រូនស៊ើបការណ៍ ដ្រូនប្រយុទ្ធ ដ្រូនពិឃាត និងដ្រូនដឹកជញ្ជូន
- លើកគម្រោងផែនការហ្វឹកហ្វឺន និងបណ្តុះបណ្តាលជំនាញឯកទេស លើការងារឧស្សាហកម្មផលិតកាំភ្លើងការពារអាកាស កាំភ្លើងលើលើស្មារការពារអាកាស កាំជ្រួចការពារអាកាស កាំភ្លើងកាំរស្មីឡាស៊ែរការពារអាកាស ដ្រូនស៊ើបការណ៍ ដ្រូនប្រយុទ្ធ ដ្រូនពិឃាត និងដ្រូនដឹកជញ្ជូន
- ក្រៅពីភារកិច្ចខាងលើនេះសហគ្រាសផលិតអាវុធការពារអាកាស ត្រូវទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិប្រគល់ជូន។

សហគ្រាសផលិតអាវុធការពារអាកាស ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន អមដោយអនុប្រធានមួយចំនួន មានឋានៈស្មើអនុប្រធាននាយកដ្ឋាន។

**មាត្រា២២.-**

សហគ្រាសផលិតនាវាមានតួនាទី និងភារកិច្ចដូចតទៅ៖

- មានតួនាទីជាសេនាធិការឱ្យមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ លើការងារផលិតនិងតម្លើងនាវា មធ្យោបាយដឹកជញ្ជូនផ្លូវទឹកគ្រប់ប្រភេទ សម្រាប់ធានាដល់វិស័យការពារជាតិ និងសេវាសាធារណៈផ្សេងៗ
- ធ្វើទំនើបកម្ម រចនា កែច្នៃ អភិវឌ្ឍន៍ ផលិត និងតម្លើងរាល់នាវាធុនតូច ធុនមធ្យម ធុនធ្ងន់គ្រប់ប្រភេទដូចជា នាវាចម្បាំង នាវាល្បាត នាវាមុជទឹក នាវាស៊ើបការណ៍ នាវាដឹកជញ្ជូន-ធ្វើដំណើរ នាវាស្រាវជ្រាវ នាវាសង្គ្រោះ នាវាកំសាន្ត តួនាវា សំបកនាវា គ្រឿងបន្លាស់នាវា ស្របតាមស្តង់ដារផលិតកម្ម និងបទដ្ឋានបច្ចេកទេស ដោយគោរពតាមផែនការរបស់ក្រសួងការពារជាតិ
- ធ្វើជាអាណាព្យាបាល រៀបចំ ដឹកនាំ ត្រួតពិនិត្យ និងសម្របសម្រួលបណ្តាសហគ្រាស រោងចក្រ ក្រុមហ៊ុន ផលិតនិងតម្លើងនាវាគ្រប់ប្រភេទ ដែលពាក់ព័ន្ធឧស្សាហកម្មការពារជាតិ

- ស្រាវជ្រាវ ធ្វើតេស្ត វិភាគ និងពិសោធន៍រកឱ្យឃើញនូវរបកគំហើញថ្មីៗ ដើម្បីជម្រុញការអភិវឌ្ឍ ឧស្សាហកម្មនាវា ស្របតាមការវិវឌ្ឍវិស័យយោធារបស់សកលលោក
- ដាក់ឱ្យដំណើរការសាកល្បង កំណត់លក្ខណៈវិនិច្ឆ័យ វាយតម្លៃ និងទទួលស្គាល់ប្រសិទ្ធភាព គុណភាព និងលក្ខណៈសម្បត្តិនាវាដែលបានផលិត និងតម្លើងរួចរាល់
- សហការណ៍ជាមួយបណ្តាស្ថាប័នជាតិ និងអន្តរជាតិទាំងក្នុង និងក្រៅប្រទេស លើការងារឧស្សាហកម្ម ផលិតនិងតម្លើងនាវា
- លើកគម្រោងផែនការហ្វឹកហ្វឺន និងបណ្តុះបណ្តាលជំនាញឯកទេស លើការងារឧស្សាហកម្មផលិត និងតម្លើងនាវា
- ក្រៅពីភារកិច្ចខាងលើនេះ សហគ្រាសផលិតនាវា ត្រូវទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិប្រគល់ជូន។

សហគ្រាសផលិតនាវា ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន អមដោយអនុប្រធានមួយចំនួន មានឋានៈស្មើ អនុប្រធាននាយកដ្ឋាន។

**មាត្រា២៣.-**

សហគ្រាសផលិតបរិក្ខារអគ្គិសនីមានតួនាទី និងភារកិច្ចដូចតទៅ៖

- មានតួនាទីជាសេនាធិការឱ្យមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ លើការងារឧស្សាហកម្ម ផលិតខ្សែភ្លើង គ្រង់ស្គូរអគ្គិសនី សម្ភារៈ បរិក្ខារ និងឧបករណ៍អគ្គិសនី ផលិតនិងតម្លើងម៉ាស៊ីនភ្លើង ផ្ទាំងសូឡា និងបង្គោល អគ្គិសនីគ្រប់ប្រភេទសម្រាប់បម្រើវិស័យការពារជាតិ វិស័យសេវាសាធារណៈ និងវិស័យថាមពល
- ធ្វើទំនើបកម្ម រចនា កែច្នៃ អភិវឌ្ឍន៍ផលិតខ្សែភ្លើង គ្រង់ស្គូរអគ្គិសនី សម្ភារៈ បរិក្ខារ និងឧបករណ៍អគ្គិសនី ផលិត និងតម្លើងម៉ាស៊ីនភ្លើង ផ្ទាំងសូឡា និងបង្គោលអគ្គិសនីគ្រប់ប្រភេទ ស្របតាមស្តង់ដារផលិតកម្ម និងបទដ្ឋានបច្ចេកទេស ដោយគោរពតាមផែនការរបស់ក្រសួងការពារជាតិ
- ធ្វើជាអាណាព្យាបាល រៀបចំ ដឹកនាំ ត្រួតពិនិត្យ និងសម្របសម្រួលបណ្តាសហគ្រាស រោងចក្រ ក្រុមហ៊ុនផលិតខ្សែភ្លើង គ្រង់ស្គូរអគ្គិសនី សម្ភារៈ បរិក្ខារ និងឧបករណ៍អគ្គិសនី ផលិតនិងតម្លើងម៉ាស៊ីនភ្លើង ផ្ទាំងសូឡា និងបង្គោលអគ្គិសនីគ្រប់ប្រភេទទាំងអស់ដែលពាក់ព័ន្ធឧស្សាហកម្មការពារជាតិ
- ស្រាវជ្រាវ ធ្វើតេស្ត វិភាគ និងពិសោធន៍រកឱ្យឃើញនូវរបកគំហើញថ្មីៗ ដើម្បីជម្រុញការអភិវឌ្ឍឧស្សាហកម្មផលិតខ្សែភ្លើង គ្រង់ស្គូរអគ្គិសនី សម្ភារៈ បរិក្ខារ និងឧបករណ៍អគ្គិសនី ផលិត និងតម្លើងម៉ាស៊ីនភ្លើងផ្ទាំងសូឡា និងបង្គោលអគ្គិសនីគ្រប់ប្រភេទ ស្របតាមការវិវឌ្ឍវិស័យយោធារបស់សកលលោក
- កំណត់លក្ខណៈវិនិច្ឆ័យ វាយតម្លៃ និងទទួលស្គាល់ប្រសិទ្ធភាព បរិមាណ គុណភាព និងលក្ខណៈសម្បត្តិនៃផលិតផលក្នុងការផលិតខ្សែភ្លើង គ្រង់ស្គូរអគ្គិសនី សម្ភារៈ បរិក្ខារ និងឧបករណ៍អគ្គិសនី ការផលិតនិងតម្លើងម៉ាស៊ីនភ្លើង ផ្ទាំងសូឡា និងបង្គោលអគ្គិសនីគ្រប់ប្រភេទដែលបានផលិត និងតម្លើងរួចរាល់
- សហការណ៍ជាមួយបណ្តាស្ថាប័នជាតិនិងអន្តរជាតិទាំងក្នុង និងក្រៅប្រទេស លើការងារឧស្សាហកម្មផលិតខ្សែភ្លើង គ្រង់ស្គូរអគ្គិសនី សម្ភារៈ បរិក្ខារ និងឧបករណ៍អគ្គិសនី ផលិតនិងតម្លើងម៉ាស៊ីនភ្លើង ផ្ទាំងសូឡា និងបង្គោលអគ្គិសនីគ្រប់ប្រភេទ
- លើកគម្រោងផែនការហ្វឹកហ្វឺន និងបណ្តុះបណ្តាលជំនាញឯកទេស លើការងារឧស្សាហកម្មផលិតខ្សែភ្លើង គ្រង់ស្គូរអគ្គិសនី សម្ភារៈ បរិក្ខារ និងឧបករណ៍អគ្គិសនី ផលិតនិងតម្លើងម៉ាស៊ីនភ្លើង ផ្ទាំងសូឡា និងបង្គោលអគ្គិសនីគ្រប់ប្រភេទ
- ក្រៅពីភារកិច្ចខាងលើនេះសហគ្រាសផលិតបរិក្ខារអគ្គិសនី ត្រូវទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិប្រគល់ជូន។

សហគ្រាសផលិតបរិក្ខារអគ្គិសនី ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន អមដោយអនុប្រធានមួយចំនួន មានឋានៈស្មើ អនុប្រធាននាយកដ្ឋាន។

**មាត្រា២៤.-**

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ឧស្សាហកម្មការពារជាតិមានតួនាទី និងភារកិច្ចដូចតទៅៈ

- វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ឧស្សាហកម្មការពារជាតិ ភាសាអង់គ្លេសសរសេរថា "INSTITUTE OF RESEARCH AND DEVELOPMENT FOR NATIONAL DEFENSE INDUSTRIAL"
- មានតួនាទីជាសេនាធិការឱ្យមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ លើការងារស្រាវជ្រាវ អភិវឌ្ឍន៍ រចនាម៉ូដ គំរូម៉ូដែលផលិតកម្ម អាវុធយុទ្ធភណ្ឌ យុទ្ធោបករណ៍ សព្វាវុធ យានយន្ត នាវា គ្រឿងចក្រ គ្រាប់ រំសេវ គ្រឿងបង្គុំផ្ទុះ លោហធាតុ សម្ភារៈ ឧបករណ៍ អេឡិចត្រូនិច បរិក្ខារអគ្គិសនី ដើម្បីកំណត់គុណភាពលក្ខណៈវិនិច្ឆ័យ និងគោលដៅបម្រើឱ្យការសិក្សាស្រាវជ្រាវវិស័យឧស្សាហកម្មការពារជាតិ
- សិក្សាស្រាវជ្រាវ ធ្វើតេស្ត វិភាគ និងពិសោធន៍រកឱ្យឃើញនូវរបកគំហើញថ្មីៗ ដើម្បីជម្រុញការអភិវឌ្ឍឧស្សាហកម្មការពារជាតិ ស្របតាមការវិវឌ្ឍវិស័យយោធារបស់សកលលោក
- សិក្សាស្រាវជ្រាវការងារបច្ចេកវិទ្យាឌីជីថល បញ្ញាសប្បនិម្មិត និងស្វ័យប្រវត្តិកម្ម ឧស្សាហកម្មអេឡិចត្រូនិច ឧស្សាហកម្មបច្ចេកវិទ្យា ឧស្សហកម្មសព្វាវុធ ឧស្សាហកម្មយានយន្ត និងឧស្សាហកម្មនាវា
- សហការស្រាវជ្រាវ និងអភិវឌ្ឍន៍ជាមួយបណ្ដាអង្គភាពចំណុះខ្សែបណ្ដោយផ្ទៃក្នុងមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ ក្រសួងការពារជាតិ
- សហការស្រាវជ្រាវ និងអភិវឌ្ឍន៍ជាមួយបណ្ដាស្ថាប័នជំនាញផ្សេងៗក្នុងកងយោធពលខេមរភូមិន្ទ
- សហការស្រាវជ្រាវ និងអភិវឌ្ឍន៍ជាមួយបណ្ដាក្រុមហ៊ុន រោងចក្រ សហគ្រាស ស្ថាប័នជាតិ អន្តរជាតិក្នុងប្រទេស និងក្រៅប្រទេស ទ្វេភាគី ត្រីភាគី និងពហុភាគីដែលមានការពាក់ព័ន្ធឧស្សាហកម្មការពារជាតិ
- លើកគម្រោងផែនការហ្វឹកហ្វឺន និងបណ្ដុះបណ្ដាលជំនាញឯកទេសស្រាវជ្រាវ និងអភិវឌ្ឍន៍ លើការងារឧស្សាហកម្មការពារជាតិ សំដៅប្រមូលផ្ដុំ ពង្រឹងពង្រីក បង្កើនសមត្ថភាព និងគុណភាព និងកសាងបណ្ដាញធនធានមនុស្ស
- ក្រៅពីភារកិច្ចខាងលើនេះវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ឧស្សាហកម្មការពារជាតិ ត្រូវទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិប្រគល់ជូន។

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍឧស្សាហកម្មការពារជាតិ ដឹកនាំដោយនាយកមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន អមដោយនាយករងមួយចំនួន មានឋានៈស្មើ អនុប្រធាននាយកដ្ឋាន។

**មាត្រា២៥.-**

ការិយាល័យព័ត៌មានវិទ្យាមានតួនាទី និងភារកិច្ចដូចតទៅៈ

- មានតួនាទីជាសេនាធិការមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិលើវិស័យព័ត៌មានវិទ្យា
- មានភារកិច្ចស្រាវជ្រាវ ចងក្រង និងប្រមូលផ្ដុំព័ត៌មានតាមបណ្ដាកងឯកភាព ដែលមានទំនាក់ទំនងជាមួយវិស័យឧស្សាហកម្មការពារជាតិ
- ហ្វឹកហ្វឺន បំប៉ន និងបណ្ដុះបណ្ដាលជំនាញព័ត៌មានវិទ្យាសំដៅពង្រឹងពង្រីកសមត្ថភាពជំនាញឱ្យស្របតាមការរីកចម្រើនរបស់កងយោធពលខេមរភូមិន្ទ
- តាមដានការវិវឌ្ឍន៍វិស័យឧស្សាហកម្មការពារជាតិទូទាំងពិភពលោក ដើម្បីធ្វើជាបទពិសោធន៍ និងផ្សព្វផ្សាយដល់កងកម្លាំងក្នុងកងយោធពលខេមភូមិន្ទ ធ្វើជាមូលដ្ឋានចំណេះដឹង
- ក្រៅពីភារកិច្ចខាងលើនេះការិយាល័យព័ត៌មានវិទ្យា ត្រូវទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិប្រគល់ជូន។

ការិយាល័យព័ត៌មានវិទ្យា ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន។

**មាត្រា២៦.-**

ការិយាល័យប្រវត្តិសាស្ត្រយោធាមានតួនាទី និងភារកិច្ចដូចតទៅ៖

- មានតួនាទីជាសេនាធិការជូនមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិលើការងារសិក្សា ស្រាវជ្រាវ ចងក្រងឯកសារទាក់ទងនឹងប្រវត្តិសាស្ត្ររបស់កងឯកភាពកងទ័ពតាមសម័យកាលនីមួយៗ
- មានភារកិច្ចទំនាក់ទំនងជាខ្សែយៈជំនាញប្រវត្តិសាស្ត្រយោធា ដើម្បីសិក្សាស្រាវជ្រាវ ចងក្រងឯកសារ ទាក់ទងនិងប្រវត្តិសាស្ត្រ យុទ្ធសាស្ត្រ និងយុទ្ធវិធីរបស់កងទ័ព
- ធ្វើការសិក្សា និងវិភាគព័ត៌មានផ្សេងៗ ដែលទាក់ទងនឹងប្រវត្តិសាស្ត្រកងទ័ពឱ្យបានត្រឹមត្រូវ និងសុក្រឹតតាមសម័យកាលនីមួយៗ
- ថែរក្សាទុកដាក់នូវរាល់ឯកសារដែលបានសិក្សាស្រាវជ្រាវ ចងក្រង ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស
- រាយការណ៍ជាប្រចាំមកវិទ្យាស្ថានប្រវត្តិសាស្ត្រយោធា នៃអគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស ឱ្យបានទៀងទាត់តាមការកំណត់
- ក្រៅពីភារកិច្ចខាងលើនេះការិយាល័យប្រវត្តិសាស្ត្រយោធា ត្រូវទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិប្រគល់ជូន។

ការិយាល័យប្រវត្តិសាស្ត្រយោធា ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន ។

**មាត្រា២៧.-**

វរសេនាតូចដឹកជញ្ជូនមានតួនាទី និងភារកិច្ចដូចតទៅ៖

- វរសេនាតូចដឹកជញ្ជូនមានតួនាទីជាសេនាធិការជូនមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ លើការងារដឹកជញ្ជូននូវរាល់ផលិតផលឧស្សាហកម្ម គ្រាប់រំសេវ គ្រឿងផ្ទុះ សម្ភារៈ បរិក្ខារ ឧបករណ៍ យុទ្ធោបករណ៍ គ្រឿងចក្រគ្រប់ប្រភេទសំដៅធានាប្រគល់ជូនស្ថាប័ន អង្គភាព ក្រុមហ៊ុន សហគ្រាស រោងចក្រក្នុង មជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ និងកងយោធពលខេមរភូមិន្ទ
- ទទួលបទបញ្ជាពីថ្នាក់ដឹកនាំមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ ធានាលើការងារដឹកជញ្ជូនឱ្យ បានល្អប្រសើរ ។
- ក្រៅពីភារកិច្ចខាងលើនេះវរសេនាតូចដឹកជញ្ជូន ត្រូវទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិប្រគល់ជូន។

វរសេនាតូចដឹកជញ្ជូនដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធានការិយាល័យ អមដោយអនុប្រធានមួយចំនួន មានឋានៈស្មើ អនុប្រធានការិយាល័យ។

**មាត្រា២៨.-**

វរសេនាតូចការពារមានតួនាទី និងភារកិច្ចដូចតទៅ៖

- វរសេនាតូចការពារមានតួនាទីជាសេនាធិការជូនមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ លើការងារការពារនូវរាល់ផលិតផលឧស្សាហកម្ម គ្រាប់រំសេវ គ្រឿងផ្ទុះ សម្ភារៈ បរិក្ខារ ឧបករណ៍ យុទ្ធោបករណ៍ គ្រឿងចក្រគ្រប់ប្រភេទសំដៅធានាការពារសុវត្ថិភាពជូនស្ថាប័ន អង្គភាព ក្រុមហ៊ុន សហគ្រាស រោងចក្រ ក្នុងមជ្ឈមណ្ឌលឧស្សាហកម្មកម្មការពារជាតិ
- ទទួលបទបញ្ជាពីថ្នាក់ដឹកនាំមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ លើការងារធានាសុវត្ថិភាពខ្ពស់បំផុតឱ្យបានល្អប្រសើរ
- ក្រៅពីភារកិច្ចខាងលើនេះវរសេនាតូចការពារ ត្រូវទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិប្រគល់ជូន។

វរសេនាតូចការពារ ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធានការិយាល័យ អមដោយអនុប្រធានមួយចំនួន មានឋានៈស្មើ អនុប្រធានការិយាល័យ។

**មាត្រា២៩.-**

បណ្ដាពេងជាងមានតួនាទី និងភារកិច្ចដូចតទៅ៖

- បណ្ដាពេងជាងមានតួនាទីជាសេនាធិការជូនមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ និងមានភារកិច្ចលើការងារជួសជុល ថែទាំគ្រប់ប្រភេទរបស់មជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ។
- ក្រៅពីភារកិច្ចខាងលើនេះបណ្ដាពេងជាង ត្រូវទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិប្រគល់ជូន។

បណ្ដាពេងជាង ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធានការិយាល័យ អមដោយអនុប្រធានមួយចំនួនមានឋានៈស្មើ អនុប្រធានការិយាល័យ។

**មាត្រា៣០.-**

បណ្ដាឃ្លាំងមានតួនាទី និងភារកិច្ចដូចតទៅ៖

- បណ្ដាឃ្លាំងមានតួនាទីជាសេនាធិការជូនមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ និងមានភារកិច្ចលើការងារគ្រប់គ្រងថែរក្សាទុកនូវរាល់ផលិតផលឧស្សាហកម្ម គ្រាប់រំសេវ គ្រឿងផ្ទុះ សម្ភារៈ បរិក្ខារ ឧបករណ៍ យុទ្ធោបករណ៍ គ្រឿងចក្រគ្រប់ប្រភេទធានាសុវត្ថិភាពខ្ពស់ មុនប្រគល់ជូនកងយោធពលខេមរភូមិន្ទ
- ក្រៅពីភារកិច្ចខាងលើនេះបណ្ដាឃ្លាំងត្រូវទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលមជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិប្រគល់ជូន។

បណ្ដាឃ្លាំង ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធានការិយាល័យ អមដោយអនុប្រធានមួយចំនួនមានឋានៈស្មើ អនុប្រធានការិយាល័យ។

**មាត្រា៣១.-**

ក្នុងករណីតម្រូវការចាំបាច់ មជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ ស្នើសុំគោលការណ៍ជ្រើសរើស ជំនាញការជាតិ ជំនាញការអន្តរជាតិ មន្ត្រីជាប់កិច្ចសន្យា មន្ត្រីក្នុងមុខងារសាធារណៈ និងជ្រើសរើសបញ្ចូលក្នុងក្របខ័ណ្ឌកងយោធពលខេមរភូមិន្ទ ។ លក្ខណៈសម្បត្តិជ្រើសរើស ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការពារជាតិ។

**មាត្រា៣២.-**

មជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ មានត្រាមួយដោយឡែក ដើម្បីបំពេញការងាររបស់ខ្លួន ។

រូបសញ្ញាសំគាល់អង្គភាព រូបសញ្ញាសម្រាប់បំពាក់លើសំលៀកបំពាក់ និងត្រាបណ្ដាអង្គភាពចំណុះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការពារជាតិ។

## ជំពូកទី ៤
## ប្រភពធនធាន

**មាត្រា៣៣.-**

ក្រសួងការពារជាតិធានាផ្គត់ផ្គង់ប្រភពធនធានមនុស្ស និងគោលរបបនានា ធានាផ្គត់ផ្គង់ប្រភពសម្ភារៈ មធ្យោបាយ គ្រឿងបំពាក់ និងថវិកាផ្សេងៗ សម្រាប់ដំណើរការការងារ ជំរុញដល់សង្វាក់ផលិតកម្មការស្រាវជ្រាវ និងអភិវឌ្ឍន៍ឧស្សាហកម្មការពារជាតិ។

មជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ អាចទំនាក់ទំនងរកប្រភពជំនួយពីបណ្ដាលប្រទេសផ្សេងៗ និងដៃគូអភិវឌ្ឍន៍នានា ព្រមទាំងរកប្រាក់កំរៃពីសេវាកម្មផ្សេងៗ ផ្ដល់ដោយអង្គការសាធារណៈ និងឯកជន។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា៣៤.-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃពុធ ៤ រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៧ ខែមិថុនា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីសូមហត្ថលេខា**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**សម្តេចពិជ័យសេនា ទៀ បាញ់**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៣៥
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ......១២៣ អនក្រ.បក......ចុះថ្ងៃទី......៧......ខែ មិថុនា....ឆ្នាំ២០២៣**

## អង្គការលេខរបស់

## មជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ ចំណុះក្រសួងការពារជាតិ

**មជ្ឈមណ្ឌលឧស្សាហកម្មការពារជាតិ**

- លេខាធិការដ្ឋាន
- ជំនាញគ្រប់គ្រងបុគ្គលិក
- ជំនាញគ្រប់គ្រងភស្តុភារ ហិរញ្ញវត្ថុ និងសុខាភិបាល
- ជំនាញត្រួតពិនិត្យ
- ជំនាញគ្រប់គ្រងសម្ភារៈ
- មូលដ្ឋានតេស្តសាកល្បង និងពិសោធន៍
- នាយកដ្ឋានផែនការ
- នាយកដ្ឋានត្រួតពិនិត្យគុណភាព និងស្តង់ដារផលិតកម្ម
- នាយកដ្ឋានសហប្រតិបត្តិការឧស្សាហកម្មយោធា ស៊ីវិល
- សហគ្រាសអាវុធថ្មើរជើង
- សហគ្រាសយន្តសាស្ត្រ
- សហគ្រាសផលិតនាវា
- សហគ្រាសផលិតកម្មគីមីសាស្ត្រ
- សហគ្រាសផលិតវរសេវផ្ទះ
- សហគ្រាសផលិតគ្រឿងអេឡិចត្រូនិច
- សហគ្រាសកាំភ្លើងធ្ងន់
- សហគ្រាសយានយន្ត
- សហគ្រាសផលិតអាវុធការពារអាកាស
- សហគ្រាសផលិតបរិក្ខារអគ្គិសនី
- វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ឧស្សាហកម្មការពារជាតិ
- ការិយាល័យព័ត៌មានវិទ្យា
- ការិយាល័យប្រវត្តិសាស្ត្រយោធា
- វរសេនាតូចដឹកជញ្ជូន
- វរសេនាតូចការពារ
- បណ្ណារោងជាង
- បណ្ណាឃ្លាំង